**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៨៦១ **អយក.ហវ**

ថ្ងៃសុក្រ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០២១

**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពថវិកា**

**កម្មវត្ថុ ៖** ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡាជំនាន់ទី៣ (EFMS V3) លើមុខងារគ្រប់គ្រងថវិការជ្ជទេយ្យបុរេប្រទាននៅតាមអង្គភាពថវិការដ្ឋបាលថ្នាក់កណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង ៖** ប្រកាសលេខ៦៦៣ សហវ.ហក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពថវិកាជ្រាបថា៖ ក្រសួង បានកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡាជំនាន់ទី៣ (EFMS V3) លើមុខងារគ្រប់គ្រងថវិការជ្ជទេយ្យបុរេប្រទាន ដែលមានលក្ខណៈជា Web Application (Online) ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពស្វ័យប្រវត្តិកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុតាមសម័យបច្ចេកវិទ្យាព័ត៌មានវិទ្យា ឱ្យកាន់តែមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ជាពិសេសប្រព័ន្ធមានសមត្ថភាពក្នុងការកត់ត្រាកិច្ចបញ្ជិកាគណនេយ្យ ការផលិតបញ្ជីគណនេយ្យ របាយការណ៍គណនេយ្យ និងរបាយការណ៍សម្រាប់ទូទាត់រជ្ជទេយ្យបុរេប្រទាន។ល។ ព្រមទាំងបានជួយសម្រួលការងារជាច្រើនរបស់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យកាន់ប្រសើរជាងមុនក្នុងការគ្រប់គ្រងថវិការជ្ជទេយ្យបុរេប្រទាន។ ក្នុងន័យនេះ ក្រសួងសូមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡាជំនាន់ទី៣ (EFMS V3) លើមុខងារគ្រប់គ្រងថវិការជ្ជទេយ្យបុរេប្រទានជូនអង្គភាពថវិការដ្ឋបាលថ្នាក់កណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត សម្រាប់ប្រើប្រាស់ចាប់ពីឆ្នាំ២០២១ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានអង្គភាពថវិកាមេត្តាជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- គ្រប់អគ្គនាយកដ្ឋាននិងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាព័ត៌មាន "
- កាលប្បវត្តិ
- ឯកសារ .នា. ហិរញ្ញវត្ថុ